ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# អនុស្សរណៈនៃការយោគយល់គ្នា

រវាង

អង្គការដែនដីមនុស្ស-ហូឡង់ប្រចាំកម្ពុជា

និង

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

ស្តីពី

សកម្មភាពបង្ការទប់ស្កាត់ ការកេងប្រវ័ញ្ច

និងការរំលោភបំពានផ្លូវភេទលើកុមារក្នុងវិស័យទេសចរណ៍

២០១៩ - ២០២១

# សង្ខេបគម្រោង

| | |
|---|---|
| ឈ្មោះអង្គការ: | អង្គការដែនដីមនុស្ស-ហូឡង់ដ៏ប្រចាំកម្ពុជា |
| ប្រភេទអង្គការ: | អង្គការបរទេសក្នុងស្រុក |
| អាសយដ្ឋាន: | ផ្ទះលេខ៥៥ ផ្លូវលេខ៣៤៨ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ |
| លេខទូរស័ព្ទទំនាក់ទំនង: | (៨៥៥) ២៣ ២២២ ៥៥៣, (៨៥៥) ៧៧ ៦៥៤ ៨៤៤ |
| អ៊ីម៉ែល: | asia@tdh.nl |
| ឈ្មោះគម្រោងសកម្មភាព: | សកម្មភាពបង្ការទប់ស្កាត់ ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទលើកុមារក្នុងវិស័យទេសចរណ៍ |
| លេខកូដគម្រោង: | **PC0202** |
| ទីតាំងគម្រោង: | ខេត្តសៀមរាប ខេត្តព្រះសីហនុ និង រាជធានីភ្នំពេញ |
| ដៃគូអនុវត្តគម្រោង: | អង្គការសកម្មភាពដើម្បីកុមារ (APLE) |
| ថវិកាអនុវត្តគម្រោង: | 970,992 អឺរ៉ូ |
| កាលបរិច្ឆេទចាប់ផ្តើម: | ថ្ងៃទី០១ ខែ សីហា ឆ្នាំ ២០១៩ |
| កាលបរិច្ឆេទបញ្ចប់: | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ |
| ចំនួនបុគ្គលិកខ្មែរ: | ២០នាក់ (ស្រី ០៩នាក់) |
| ចំនួនបុគ្គលិកបរទេស: | ០៤នាក់ |
| អ្នកគ្រប់គ្រងគម្រោង៖ | Mr. Van der Lee hendrikusMartinus Cornelis |

# អនុស្សរណៈនៃការយោគយល់គ្នា

# រវាង

# អង្គការដែនដីមនុស្ស-ហូឡង់ដ៏ ប្រចាំកម្ពុជា

# និង

# គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

# ស្តីពី

# សកម្មភាពបង្ការទប់ស្កាត់ការកេងប្រវ័ញ្ច និងការរំលោភបំពាន ផ្លូវភេទលើកុមារក្នុងវិស័យទេសចរណ៍

## ផ្នែកទី១

## បុព្វកថា

**ដោយហេតុថាៈ** គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានសំដែងនូវបំណងប្រាថ្នាដូចបានចែងក្នុងអនុស្សរណៈនៃការយោគយល់គ្នានេះថា អង្គការដែនដីមនុស្ស-ហូឡង់ដ៏ប្រចាំកម្ពុជា បានចូលរួមចំណែកការងារមនុស្សធម៌ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីសុខុមាលភាពសង្គមតាមរយៈការបង្ការទប់ស្កាត់ និងការឆ្លើយតបធ្វើអោយកាន់តែប្រសើរឡើងនូវការគោរពសិទ្ធិកុមារ និងប្រាកដថាកុមារទទួលបាននូវការការពារ។

**ដោយហេតុថាៈ** អង្គការដែនដីមនុស្ស-ហូឡង់ដ៏ប្រចាំកម្ពុជា និង គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមរយៈកិច្ចសហប្រតិបត្តិការក្នុងការបង្ការទប់ស្កាត់ ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ចផ្សេងៗ និងការរំលោភបំពានផ្លូវភេទលើកុមារក្នុងវិស័យទេសចរណ៍។

**ដោយហេតុថាៈ** ដើម្បីសកម្មភាពឆ្លើយតបមានប្រសិទ្ធភាពខ្ពស់ អង្គការដែនដីមនុស្ស-ហូឡង់ដ៏ប្រចាំកម្ពុជា និងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមរយៈយន្តការជាតិ និងថ្នាក់ក្រោមជាតិសហការលើសកម្មភាពជាក់ស្តែងដូចខាងក្រោមៈ

**១) គោលដៅគម្រោងៈ**

ធ្វើសកម្មភាពបង្ការទប់ស្កាត់ការកេងប្រវ័ញ្ចនិងការរំលោភបំពានផ្លូវភេទលើកុមារក្នុងវិស័យទេសចរណ៍។

**២) ការអនុវត្តសកម្មភាពគម្រោង៖**

១. សហការជាមួយរដ្ឋាភិបាលថ្នាក់ជាតិ ក្នុងការសម្របសម្រួលកិច្ចសហការរបស់អ្នកពាក់ព័ន្ធ ដើម្បីឆ្លើយតបទៅនឹងការបង្ការទប់ស្កាត់ ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទលើកុមារ ក្នុងវិស័យទេសចរណ៍នៅក្នុងប្រទេស។

២. សហការជាមួយមន្ត្រីរាជរដ្ឋាភិបាល ដែលធ្វើការងារនៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ដើម្បីពង្រឹងសមត្ថភាពស៊ើបអង្កេត ការសម្ភាសន៍ដោយផ្តោតលើវិធីសាស្ត្រដែលមានលក្ខណៈកុមារមេត្រី ដើម្បីការពារកុមារអោយបានកាន់តែល្អប្រសើរ។

៣. សហការជាមួយអ្នកពាក់ព័ន្ធ ដើម្បីជួយកុមាររងគ្រោះដោយការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទលើកុមារក្នុងវិស័យទេសចរណ៍ ដើម្បីអោយទទួលបានសេវាគាំទ្រផ្នែកសង្គមអារម្មណ៍ផ្លូវចិត្ត សេវាជំនួយផ្នែកច្បាប់។

៤. លើកកម្ពស់ការយល់ដឹងរបស់ប្រជាជននៅក្នុងសហគមន៍គោលដៅ និងផ្តល់សិទ្ធិអំណាចអោយពួកគេអាចចូលរួមចំណែកការការពារកុមារអោយមានសុវត្ថិភាពពីការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទ។

## ផ្នែកទី២

### ការទទួលខុសត្រូវរបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

### មានដូចខាងក្រោម៖

**មាត្រា១៖** អនុញ្ញាតឲ្យអង្គការដែនដីមនុស្ស-ហូឡង់ដ៍ប្រចាំកម្ពុជា បំពេញការងាររបស់ខ្លួនដោយអនុវត្តស្របទៅតាមច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២៖** គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សម្របសម្រួលគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរាជធានី-ខេត្ត ក្នុងការចូលរួមសហការជាមួយ អង្គការដែនដីមនុស្ស-ហូឡង់ដ៍ប្រចាំកម្ពុជា និងអង្គការដៃគូពាក់ព័ន្ធរបស់អង្គការនេះ ក្នុងការរៀបចំកិច្ចប្រជុំពិភាក្សា

ជាមួយក្រុមបច្ចេកទេស ស្ដីពីការចាត់អាទិភាពការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទលើកុមារក្នុងវិស័យទេសចរណ៍ ទៅក្នុងផែនការសកម្មភាពរបស់ខ្លួន។

**មាត្រា៣៖** សម្របសម្រួលផ្នែកពាក់ព័ន្ធនានា ដើម្បីឆ្លើយតបកិច្ចសហការក្នុងការបង្ការទប់ស្កាត់ ការកេងប្រវ័ញ្ចផ្សេងៗ និងការរំលោភបំពានផ្លូវភេទលើកុមារក្នុងវិស័យទេសចរណ៍។

## ផ្នែកទី៣

## ការទទួលខុសត្រូវរបស់អង្គការដែនដីមនុស្ស-ហូឡង់ដ៍ប្រចាំកម្ពុជា មានភារកិច្ចដូចខាងក្រោម៖

**មាត្រា៤៖** អង្គការដែនដីមនុស្សហូឡង់ដ៍-ប្រចាំកម្ពុជាមានជំនួយថវិកាពីប្រទេសហូឡង់ដ៍ ក្នុងការអនុវត្តសកម្មភាពរបស់គម្រោងឲ្យមានប្រសិទ្ធភាពចំគោលដៅ និងត្រូវគោរពឲ្យបានខ្ជាប់ខ្ជួននូវច្បាប់ និងបទបញ្ញត្តិទាំងឡាយរបស់ព្រះរាជាណាចក្រកម្ពុជា និងមិនអនុញ្ញាតឲ្យភ្នាក់ងាររបស់ខ្លួនមានការចូលរួម នូវរាល់សកម្មភាពទាំងឡាយណាដែលអាចប៉ះពាល់ដល់សុវត្ថិភាព ស្ថិរភាព និងសណ្ដាប់ធ្នាប់សង្គម ឬសកម្មភាពដទៃទៀតដែលអាចបង្កអន្តរាយដល់សន្តិសុខជាតិ ឯកភាពជាតិ វប្បធម៌ និងប្រពៃណីរបស់ប្រជាជនកម្ពុជា។

**មាត្រា៥៖** អង្គការដែនដីមនុស្ស-ហូឡង់ដ៍ប្រចាំកម្ពុជា ប្រតិបត្តិនូវរាល់សកម្មភាពមនុស្សធម៌ជួយដល់កុមាររងគ្រោះ និងងាយរងគ្រោះស្របតាមផែនការសកម្មភាព និងគោលនយោបាយរបស់ខ្លួន ដោយប្រកាន់ខ្ជាប់នូវគោលការណ៍ នៃកិច្ចសហប្រតិបត្តិការឲ្យស្របតាមច្បាប់។

**មាត្រា៦៖** អង្គការដែនដីមនុស្ស-ហូឡង់ដ៍ប្រចាំកម្ពុជា ត្រូវពង្រឹងភាពជាដៃគូរវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមរយៈការធ្វើសកម្មភាពរបស់ដៃគូអនុវត្តរបស់ខ្លួន ត្រូវផ្ដល់ព័ត៌មានដល់គោលដៅ ដើម្បីសម្របសម្រួលដល់ការផ្លាស់ប្ដូរព័ត៌មានរវាងថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិពាក់ព័ន្ធនឹងសកម្មភាព ដែលបានអនុវត្ត ព្រមទាំងមានរបាយការណ៍ប្រចាំ ត្រីមាស និងឆ្នាំ ជូនគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រួមមានសកម្មភាពដែលបានអនុវត្ត សមិទ្ធិផល និងបញ្ហាប្រឈមនានាដែលបានជួបប្រទះ។

**មាត្រា៧៖** អង្គការដែនដីមនុស្ស-ហូឡង់ដ៍ប្រចាំកម្ពុជា ចូលរួមតែសកម្មភាពបង្ការទប់ស្កាត់ ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ដែលបានទទួលការសហការជាមួយ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដើម្បីជាប្រយោជន៍ជួយដល់កុមាររងគ្រោះ និងងាយរងគ្រោះតែប៉ុណ្ណោះ។ ចៀសវាងដាច់ខាតពីសកម្មភាពដើម្បីប្រាក់ចំណេញ ព្រមទាំងសកម្មភាពនយោបាយ ដែលមិនបម្រើដល់គោលដៅមនុស្សធម៌ក្នុងគោលបំណងជួយដល់កុមាររងគ្រោះ និងងាយរងគ្រោះ

ដូចដែលអង្គការដែនដីមនុស្ស-ហូឡង់ដ៏ប្រចាំកម្ពុជាបានប្រកាស ជាពិសេសកុមារដែលទទួលរងការរំលោភបំពានផ្លូវភេទក្នុងវិស័យទេសចរណ៍។

**មាត្រា៨៖** អង្គការដែនដីមនុស្ស-ហូឡង់ដ៏ប្រចាំកម្ពុជា ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ស្ដីពីការផ្លាស់ប្ដូរណាមួយទាក់ទងនឹងអាសយដ្ឋាន ឬនាយកប្រចាំប្រទេសដែលបានចាត់តាំង។

## ផ្នែកទី៤

## អវសានប្បញ្ញត្តិ

**មាត្រា៩៖** រាល់វិវាទរវាង គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការដែនដីមនុស្ស-ហូឡង់ដ៏ប្រចាំកម្ពុជា ទាក់ទងទៅនឹងការអនុវត្ត ឬការបកស្រាយ អនុស្សរណៈនេះនឹងត្រូវបានដោះស្រាយតាមរយៈការចរចា ដោយសន្តិវិធីរវាងភាគីទាំងពីរ។

**មាត្រា១០៖** អនុស្សរណៈនៃការយោគយល់គ្នានេះ អាចបញ្ចប់ដោយភាគីណាមួយក៏បាន គឺបន្ទាប់ពី៦០ថ្ងៃ ដែលភាគីនោះផ្ដល់សេចក្ដីជូនដំណឹងជាលាយលក្ខណ៍អក្សរបញ្ជូនទៅភាគីម្ខាងទៀត។

**មាត្រា១១៖** អនុស្សរណៈនេះចូលជាធរមាននៅពេលដែលភាគីទាំងពីរបានចុះហត្ថលេខា និងមានសុពលភាពរយៈពេល ០២ ឆ្នាំ ហើយនឹងត្រូវបន្តសុពលភាពដោយមានការយល់ព្រមពីភាគីទាំងពីរ។

**មាត្រា១២៖** អនុស្សរណៈនេះធ្វើឡើងជាពីរច្បាប់ដើម ជាភាសាខ្មែរ និងភាសាអង់គ្លេស ដោយអត្ថបទទាំងពីរមានតម្លៃស្មើគ្នាតាមផ្លូវច្បាប់។

ថ្ងៃ ព្រហស្បតិ៍ ១៤កើត ខែ ភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ២០១៩

| | |
|---|---|
| **តំណាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** | **តំណាងអង្គការដែនដីមនុស្សហូឡង់ដ៏-ប្រចាំកម្ពុជា** |
| អនុប្រធានអចិន្ត្រៃយ៍ | តំណាងប្រចាំប្រទេស |
| **ជូ ប៊ុនអេង** | Van der Lee hendrikusMartinus Cornelis |

Kingdom of Cambodia

Nation Religion King

terre des hommes

stops child exploitation

# Memorandum of Understanding

## Between

## Terre des hommes Netherlands in Cambodia

## And

## National Committee for Counter Trafficking

## On

## Actions to prevent Sexual Exploitation of Children in Travel and Tourism

**2019-2021**

**Project summary**

| | |
|---|---|
| Name of organization: | Terre des hommes Netherlands in Cambodia |
| Type of organization: | Foreign NGO |
| Address: | House No. 55, street 348, Tuol Svay Prey 1 quarter, Chamkarmon district, Phnom Penh |
| Telephone: | (855) 23 222 553, (855) 77 654 844 |
| Email: | asia@tdh.nl |
| Name of project: | Actions to prevent Sexual Exploitation of Children in Travel and Tourism. |
| Code of project: | PC0202 |
| Project location: | Siem Reap Province, Preah Sihanuok Province and Phnom Penh |
| Project partner: | Action pour les Enfants (APLE) |
| Budget: | 970,992 Euro |
| Starting date: | 01 August 2019 |
| Ending date: | 30 June 2021 |
| Number of Cambodian Staff: | 20 people (09 females) |
| Number of Foreign Staff: | 04 people |
| Project Manager: | Mr. Van der Lee hendrikusMartinus Cornelis |

# Memorandum of Understanding

**Between**

**Terre des hommes Netherlands in Cambodia**

**And**

**National Committee for Counter Trafficking**

**On**

**Actions to prevent Sexual Exploitation of Children in Travel and Tourism**

## Section I

## Preamble

**Whereas:** The National Committee for Counter Trafficking has expressed its desire as stated in this Memorandum of Understanding that Terre des Hommes Netherlands in Cambodia has contributed to humanitarian activities for social welfare through prevention and improvement of the respect for children's rights and ensuring that children in the Kingdom of Cambodia are under protection.

**Whereas:** The Terre des Hommes Netherlands in Cambodia and the National Committee for Counter Trafficking mutually cooperated in preventing human trafficking, exploitation and sexual abuses on children in the Travel and Tourism.

**Whereas:** For highly effective response actions, the Terre des Hommes Netherlands in Cambodia and the National Committee for Counter Trafficking through national and sub-national level mechanisms coordinate with the following specific activities:

**1)** Project objectives: To prevent Sexual Exploitation of Children in Travel and Tourism (SECTT).

**2)** Implementation of project activities:

1. Government coordinates efforts of multi-stakeholders for the prevention of and response to SECTT in country.

2. Government institutions relevant to criminal justice system have capacity to undertake child-centric investigations for better protection of SECTT victims and SECTT witnesses throughout the criminal justice process.
3. Child victims have access to appropriate support services through better coordination between NGOs, police, court and government agencies.
4. Communities monitor and prevent SECTT risks in their communities.

## Section II

## The responsibilities of the National Committee for Counter Trafficking

## As follows:

**Article 1:** Authorize the Terre des Hommes Netherlands in Cambodia to carry out its operation according to the laws and regulations of the Kingdom of Cambodia.

**Article 2:** Provide coordination to the National Committee for Counter Trafficking in the capital and provincial branches in collaborating with relevant partner organizations of the Terre des Hommes Netherlands in Cambodia to convene a meeting with the Technical Working Group on the prioritization of Sexual Exploitation of Children in Travel and Tourism in its concrete action plans.

**Article 3:** Coordinate with relevant multi-stakeholders in responding to the preventions of and response to Sexual Exploitation of Children in Travel and Tourism (SECTT).

## Section III

## The responsibilities of the Terre des hommes Netherlands in Cambodia

## As follows:

**Article 4:** The Terre des Hommes Netherlands in Cambodia is funded by the donors in the Netherlands, to implements its project activities effectively and respects the laws and

regulations of the Kingdom of Cambodia and forbids its agents to involve in any actions that may hamper the safety, stability and social order or other actions that could undermine the national security, national unity, culture and traditions of the Cambodian people.

**Article 5:** The Terre des Hommes Netherlands in Cambodia undertakes every humanitarian activity to help the victims and vulnerable children in accordance with its action plans and policies by adhering to the principles of cooperation in accordance with the law.

**Article 6:** The Terre des Hommes Netherlands in Cambodia shall strengthen the partnership with the National Committee for Counter Trafficking through partners' implementing actions, provides information to targeted areas in facilitating information exchanges between the sub-national and the national level in relation to the implementation activities and submits quarterly, and annual reports on its activities, accomplishment and challenges to the National Committee for Counter Trafficking.

**Article 7:** The Terre des Hommes Netherlands in Cambodia only involve in actions to prevent child sexual exploitation and abuses, which has been cooperated by the National Committee for Counter Trafficking for the benefits of the victims and vulnerable children. Avoiding profit based activities and political activities that do not serve the humanitarian goals and assistants to the victims and vulnerable children as declared by the Terre des Hommes Netherlands in Cambodia.

**Article 8:** The Terre des Hommes Netherlands in Cambodia shall notify the National Committee for Counter Trafficking in written of any change regarding the address of an appointed representative or country director of the organization.

## Section IV

## Final Provision

**Article 9:** Any dispute between the National Committee for Counter Trafficking and the Terre des hommes Netherlands in Cambodia arising out of the implementation and interpretation this Memorandum of Understanding shall be settled amicably by consultation or negotiation between both parties.

**Article 10:** This Memorandum of Understanding shall be terminated by either party after the period of 60 days of its notification in written to another party.

**Article 11:** This Memorandum of Understanding shall enter into force when both parties sign and valid for 2 years and can be extended by both parties' consensus.

**Article 12:** This MOU is written in duplicate, in Khmer and English, both texts are equally authentic.

Done at Phnom Penh on...12th September 2019...

| For the National Committee for Counter Trafficking | Terre des hommes Netherlands in Cambodia |
|---|---|
| **CHOU BUN ENG** | **Van der Lee hendrikusMartinus Cornelis** |
| Permanent Vice Chairperson of NCCT | Country Representative |